FAIR HOUSING COUNCIL of Oregon

1020 SW Taylor Street, Suite 700, Portland, Oregon 97205-2512

ទូរស័ព្ទ៖ 503-223-8197 ឬ 1-800-424-3247 (TTY)

បណ្ដាញអ៊ិនធឺណិត៖ http://www.fhco.org, សារអេឡិកត្រូនិក៖ information@fhco.org

# សន្លឹកពត៌មាន

**INFORMATION SHEET**

## បេសកកម្មរបស់យើង

ក្រុមប្រឹក្សាផ្ទែកទីលំនៅស្មើភាពគ្នានៃរដ្ឋអូរិហ្គិន (Fair Housing Council of Oregon-FHCO) ជាសាជីវកម្មឯកជនមិនយកចំណេញ ដែលមានបេសកកម្មដើម្បីបង្កើនវិធីទទួលទីលំនៅ ដោយប្រឆាំងទល់និងការប្រកាន់លក្ខណៈខុសច្បាប់ផ្ទែកទីលំនៅ ។ យើងធ្វើការអនុវត្តិច្បាប់ ការសិក្សា ហើយនិងសកម្មភាពទាក់ទងទៅក្រៅច្រើន ដែលបង្កើនថែមទៀតនូវច្បាប់ផ្ទែកទីលំនៅស្មើភាពគ្នាទៅក្នុងរដ្ឋអូរិហ្គិនហើយនិងខោនទីក្លាក រដ្ឋវ៉ាស្ហិងតុន ។

## "ច្បាប់ផ្ទែកទីលំនៅស្មើភាពគ្នា" គឺអំពីសិទ្ធិរបស់ពលរដ្ឋ

ច្បាប់ផ្ទែកទីលំនៅស្មើភាពគ្នាជាច្បាប់សហព័ន្ធ រដ្ឋ និងតាមតំបន់ដែលហាមឃាត់ការប្រកាន់លក្ខណៈផ្ទែកទីលំនៅ ។ វាជាការខុសច្បាប់ដែលចាត់ទុកជនម្នាក់ខុសពីគេទៅក្នុងកិច្ចការផ្ទែកទីលំនៅ *ពីព្រោះតែ* ជននោះជាសមាជិកនៃ "ចំពួកដែលគេការពារ" ។ ចំពួកដែលគេការពារគឺ៖

| សហព័ន្ធ | រដ្ឋអូរិហ្គិន | ទីក្រុង ផតឡែន្ត និងខោនវ៉ាស៊ីស និងខោនមិនមិនតុន |
|---|---|---|
| • សាសន៍ | • សាសន៍ | • អាយុ |
| • ពណ៌សម្បុរ | • ពណ៌សម្បុរ | • ការយល់ឃើញអំពីភេទ |
| • សាសនា | • សាសនា | • អត្តសញ្ញាខាងភេទ |
| • ជាតិកំណើតដើម | • ជាតិកំណើតដើម | **ក្រុងយូជីន (Eugene)** |
| • ភេទ | • ភេទ | • អាយុ |
| • លក្ខណៈគ្រួសារ | • លក្ខណៈគ្រួសារ | • ការយល់ឃើញអំពីភេទ |
| | • ពិការភាពខាងសតិបញ្ញា ឬខាងរាងកាយ | |
| (មានកូនអាយុក្រោម 18 ឆ្នាំក្នុងគ្រួសារ) | | **ក្រុងអាស់ឡែន្ត (Ashland)** |
| • ពិការភាពខាងសតិបញ្ញា ឬខាងរាងកាយ | • លក្ខណៈរៀបការ | • ការយល់ឃើញអំពីភេទ |
| | • ប្រភពនៃប្រាក់ចំណូល | |

ច្បាប់ទីលំនៅដោយស្មើភាពគ្នាការពារ ការជួល ការលក់ដូរ ហើយនិងកិច្ចការធានារ៉ាប់រង ។ ប្រភេទនៃអំពើខុសច្បាប់មានរួមទាំងការប្រកាន់លក្ខណៈតាមរយៈការបដិសេធទីលំនៅ ការបដិសេធដើម្បីចរចាគ្នា ផ្ដល់ពត៌មានក្លែងក្លាយ ការដេញចេញ ការអនុវត្តន៍ក្រិត្យវិន័យខុសប្លែក ឬជាគំរូ ។ ការផ្សាយពាណិជ្ជកម្មឬការថ្លែង ការរុតគួនទំខាន ការគំរាមកំហែង ការផ្ដល់កិច្ចបំរើ ឬការកាច់បង្វែរ ។ ដើម្បីធ្វើឲ្យជាក់ប្រាកដថាមានឱកាសស្មើភាពគ្នាចំពោះជនដែលពិការ ច្បាប់ផ្ទែកទីលំនៅស្មើភាពគ្នាចែងថាជនពិការមានសិទ្ធិដើម្បីធ្វើផ្ទះរបស់ពួកគេឲ្យអាចប្រើបានដោយពិតប្រាកដ ហើយនិងដើម្បីស្នើសុំការកែប្រែសមហេតុសមផលនៅក្នុងក្រិត្យវិន័យ ឬច្បាប់ ។

[Cambodian]

## កម្មវិធីរបស់ក្រុមប្រឹក្សាផ្នែកទីលំនៅស្មើភាពគ្នានៃរដ្ឋអូរិហ្គិនៈ

**ការអនុវត្តច្បាប់**

បុគ្គលិកនៃក្រុមប្រឹក្សាផ្នែកទីលំនៅស្មើភាពគ្នារបស់រដ្ឋអូរិហ្គិន (Fair Housing Council of Oregon-FHCO) ទទួលបណ្តឹងអំពីការប្រកាន់លក្ខណៈតាមទូរស័ព្ទប្រចាំការមិនគិតថ្លៃដែលបំរើរដ្ឋអូរិហ្គិននិងខោនទីក្លាក រដ្ឋវ៉ាស៊ីងតុន ។ FHCO ធ្វើវិភាគបណ្តឹងដែលអាចកើតមានឡើងអំពីការប្រកាន់លក្ខណៈ ហើយជួយបុគ្គលនោះដើម្បីតាមរកសិទ្ធិរបស់គេ ។ បុគ្គលិក FHCO និយាយអង់គ្លេសនិងស្ពេនីស្ព ។ FHCO ក៏មានប្រព័ន្ធទូរស័ព្ទសំរាប់ជនមានបញ្ហាខាងស្តាប់និងនិយាយ (TTY) ហើយនិងជំនួយផ្នែកបកប្រែជាង 100 ភាសា ។

នៅពេលណាដែលអាចធ្វើបាន FHCO ធ្វើការពិសោធន៍ឬការស៊ើបអង្កេតឯទៀតដែលអាចផ្តល់ភស្តុតាងពេញលក្ខណៈនៃការបំពានលើច្បាប់ទីលំនៅស្មើភាពគ្នា ។ "ការពិសោធន៍ "គឺជាវិធីបញ្ជាក់សំរាប់ស៊ើបអង្កេតបណ្តឹងតាមច្បាប់ផ្នែកទីលំនៅស្មើភាពគ្នា ។ អ្នកធ្វើការពិសោធន៍ដែលបានហ្វឹកហ្វឺនគឺប្រហាក់ប្រហែលគ្នានិងបញ្ហាមែនទែន លើកលែងតែសំរាប់ចំពូកដែលគេការពារនៅក្នុងសំនួរ ហើយត្រូវបានផ្ញើទៅភ្នាក់ងារជួលឬលក់ផ្ទះ ដែលបញ្ជាក់នៅក្នុងការចោទប្រកាន់នោះ ។ ភាពខុសគ្នាក្នុងការបំរើអាចផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីដោះស្រាយដោយជោគជ័យនូវបណ្តឹងអំពីបញ្ហាតាមច្បាប់ផ្នែកទីលំនៅស្មើភាពគ្នា តាមរយៈប្រព័ន្ធរដ្ឋបាលឬតុលាការ ។

បុគ្គលិក FHCO បញ្ជូនបុគ្គលដែលត្រូវគេបំពានលើសិទ្ធិតាមច្បាប់ផ្នែកទីលំនៅស្មើភាពគ្នាទៅកាន់ប្រភពនៃក្រសួងមានសមត្ថកិច្ចដែលត្រូវតាមសភាព ។ យើងបញ្ជូនអ្នកប្តឹងទៅមេធាវី ទៅមជ្ឈមណ្ឌលអនុវត្តច្បាប់ផ្នែកទីលំនៅស្មើភាពគ្នា (Fair Housing Enforcement Hub) នៅក្នុងក្រសួងផ្តល់ជំនួយទីលំនៅនិងការបង្កើនទីក្រុងរបស់សហរដ្ឋអាមេរិក (U.S. Department of Housing and Urban Development - HUD) ហើយនិងបញ្ជូនទៅក្រសួងសិទ្ធិពលរដ្ឋនៃក្រសួងការងារនិងឧស្សាហកម្មរដ្ឋអូរិហ្គិន (Oregon Bureau of Labor and Industries - BOLI) ។ FHCO ផ្តល់ជំនួយបច្ចេកទេសនិងបំរើជាប្រភពនៃក្រុមមេធាវីដែលទទួលយកការបញ្ជូនអំពីបញ្ហាតាមច្បាប់ផ្នែកទីលំនៅស្មើភាពគ្នា ។

**ការទាក់ទងទៅខាងក្រៅនិងការសិក្សា**

FHCO ផ្តល់ក្រដាសស្នាមអំពីបញ្ហាទីលំនៅស្មើភាពគ្នាដោយមានរួមទាំង កូនសៀវភៅ ប័ណ្ណប្រកាស និងវីឌីអូថេបទៅជូនមេធាវីខាងទីលំនៅ ភ្នាក់ងារបំរើសង្គម ម្ចាស់ផ្ទះ ក្រុមហ៊ុនចាត់ចែងផ្ទះសំបែងជីធ្លី ភ្នាក់ងារផ្ទះសំបែងជីធី ហើយនិងមន្ត្រីសាធារណៈនៅទូទាំងរដ្ឋអូរិហ្គិននិងខោនទីក្លាក រដ្ឋវ៉ាស៊ីងតុន ។ FHCO បោះពុម្ពលិខិតដំណឹងប្រចាំត្រីមាស *"The Promise of Opportunity* (ការសន្យានៃឱកាស)" ដែលរាយការណ៍អំពីករណីនៃបញ្ហាទីលំនៅស្មើភាពគ្នាថ្មីៗ និងដំណឹងអំពីទីលំនៅស្មើភាពគ្នាតាមតំបន់ ។ FHCO បើកធ្វើការប្រកួតប្រជែងអំពីប័ណ្ណប្រកាសកម្មវិធីផ្នែកទីលំនៅស្មើភាពគ្នាប្រចាំឆ្នាំ សំរាប់សិស្សថ្នាក់ទី 1 - 12 នៃរដ្ឋអូរិហ្គិន ហើយនិងបើកធ្វើព្រឹត្តិការណ៍ប្រចាំឆ្នាំដើម្បីអបអរសាទរ Nation Fair Housing Month (ខែនៃកម្មវិធីទីលំនៅស្មើភាពគ្នារបស់ជាតិ) ។

FHCO ផ្តល់ការហ្វឹកហ្វឺនគ្រប់ទ្រង់ទ្រាយទាំងអស់នៃច្បាប់ផ្នែកទីលំនៅស្មើភាពគ្នា ។ ក្នុងមួយៗឆ្នាំៗ FHCO បើកធ្វើការហ្វឹកហ្វឺនដោយបង់តម្លៃតិច ឬដោយមិនបាច់បង់ថ្លៃជូនសាធារណៈជនទូទាំងរដ្ឋអូរិហ្គិន ។ ក៏មានកម្មវិធីហ្វឹកហ្វឺនដោយបង់ថ្លៃឈ្នួលតាមកិច្ចបំរើសំរាប់ក្រុមហ៊ុនចាត់ចែងខាងផ្ទះសម្បែងជីធ្លី ម្ចាស់ផ្ទះនិងសមាគមខាងផ្ទះសម្បែងជីធ្លី ហើយនិងក្រសួងទីលំនៅ ។

## របៀបទាក់ទងជាមួយក្រុមប្រឹក្សាផ្នែកទីលំនៅស្មើភាពគ្នានៃរដ្ឋអូរិហ្គិនៈ

ទូរស័ព្ទប្រចាំការសំរាប់បណ្តឹងអំពីបញ្ហាទីលំនៅស្មើភាពគ្នាៈ 1-800-424-3247 (សម្លេងនិយាយ/TTY)

សារអេឡិចត្រូនិកៈ information@fhco.org

បណ្តាញអ៊ិនធើណិតៈ www.fhco.org

[Cambodian]